ប្រសិនបើយើងយល់ពីភាពពិតនៃពន្លឺនៃព្រះគ្រីស្ទនៅក្នុងមនុស្សគ្រប់រូបដែលយើងឃើញ . . . ហើយនៅក្នុងខ្លួនយើង . . . នោះយើងនឹងមានភាពក្លាហាន និងការបំផុសគំនិតលើសពីអ្វីដែលយើងធ្លាប់ដឹងពីមុនមក ។ ហើយវា *ត្រូវតែ* ដូច្នោះ ! ហើយវា *នឹង* ដូច្នោះ ! អ្វីៗទាំងអស់នេះគឺជាទំហំនៃសេចក្ដីពិតនៃដំណឹងល្អ ដែលមនុស្សពុំសូវយល់ឡើយ ។ ( ប៊ិយដ៍ ខេ ផាកកឺ « The Light of Christ » Ensign ខែ មេសា ឆ្នាំ ២០០៥ ទំព័រ ៨, ១៣–១៤ )

សូមសរសេរប្រយោគគំនិតពីរទៅបីអំពីរបៀបដែលការយល់ដឹងពីពន្លឺនៃព្រះគ្រីស្ទអាចមានឥទ្ធិពលលើរបៀបដែលអ្នកមើលឃើញពីអ្នកដទៃ ។

## ពន្លឺនៃព្រះគ្រីស្ទនៅក្នុងសាកលលោក

តើអ្នកធ្លាប់បានជ្រោតជ្រាបដួងចិត្តនឹងភាពស្រស់ស្អាត ឬភាពអស្ចារ្យនៃផែនដីនេះ និងសកលលោកដែរឬទេ ? តើអារម្មណ៍ទាំងនេះចេញមកពីក្នុងខ្លួនអ្នកយ៉ាងណា ?

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:៧–១០, ៤៥–៤៧ ហើយរកមើលអ្វីដែលអ្នករៀនអំពីពន្លឺនៃព្រះគ្រីស្ទ ផែនដី និងសកលលោក ។

- តើយើងអាចរៀនអ្វីខ្លះអំពីព្រះអម្ចាស់ចេញពីការបង្កបង្កើតរបស់ទ្រង់ ?
- តើការមើលឃើញឥទ្ធិពលរបស់ព្រះនៅក្នុងសកលលោកអាចជួយយើងស្គាល់ឥទ្ធិពលរបស់ទ្រង់នៅក្នុងជីវិតរបស់យើងយ៉ាងដូចម្ដេច ?



© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_321-1